# ព្រះរាជក្រម

នស/រកម/០៦១៣/០១៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី២ ឆ្នាំ១៩៩៩ នៃអនុសញ្ញាទីក្រុងឡាអេ ឆ្នាំ១៩៥៤ ស្តីពីការការពារសម្បត្តិវប្បធម៌ ក្នុងគ្រាមានជម្លោះប្រដាប់អាវុធ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៣ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៣ នាសម័យប្រជុំលើកទី៣ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ROYAUME DU CAMBODGE
ព្រះបរមរាជវាំង
LE MINISTRE DU PALAIS ROYAL

ច្បាប់
ស្តីពី
# ការអនុម័តយល់ព្រមលើពិធីសារទី ២ ឆ្នាំ ១៩៩៩ នៃអនុសញ្ញាទីក្រុងឡាអេ ឆ្នាំ ១៩៥៤ ស្តីពី ការការពារសម្បត្តិវប្បធម៌ក្នុងគ្រា មានជម្លោះប្រដាប់អាវុធ

**មាត្រា ១.-**

អនុម័តយល់ព្រមលើពិធីសារទី ២ ឆ្នាំ ១៩៩៩ នៃអនុសញ្ញាទីក្រុងឡាអេ ឆ្នាំ ១៩៥៤ ស្តីពីការការពារសម្បត្តិវប្បធម៌ ក្នុងគ្រាមានជម្លោះប្រដាប់អាវុធ ដែលព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខា នាថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ១៩៩៩ នៅទីក្រុងឡាអេ ប្រទេសហូឡង់ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តពិធីសារទី ២ នេះ ។

**មាត្រា ៣.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៣

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស/រកម.០៦១៣/០០៦

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី
ហត្ថលេខា
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ
ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
ហត្ថលេខា
ហ៊ឹម ឆែម

លេខៈ ៦៤៦ស.ណ
សំណៅចម្លងដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ មិថុនា ឆ្នាំ២០១៣
អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល
សយ សុខា

# ពិធីសារទី២ ឆ្នាំ១៩៩៩ នៃអនុសញ្ញាទីក្រុងឡាអេ ឆ្នាំ១៩៥៤
# ស្តីពីការការពារសម្បត្តិវប្បធម៌ ក្នុងគ្រាមានជម្លោះប្រដាប់អាវុធ

ទីក្រុងឡាអេ ថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៩៩

អនុសញ្ញា៖ ទីក្រុងឡាអេ ថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៥៤

ពិធីសារទី១៖ ទីក្រុងឡាអេ ថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៥៤

ភាគីទាំងឡាយ!

ដោយយល់ច្បាស់ពី ភាពចាំបាច់ក្នុងការធ្វើឲ្យប្រសើរឡើងនូវការការពារសម្បត្តិវប្បធម៌ ក្នុងគ្រាមានជម្លោះប្រដាប់អាវុធ និងការពង្រឹងប្រព័ន្ធការពារសម្បត្តិវប្បធម៌ ដែលត្រូវបានកំណត់ពិសេស

ដោយអះអាងឡើងវិញពី សារៈសំខាន់នៃបទប្បញ្ញត្តិទាំងឡាយរបស់អនុសញ្ញាស្តីពីការការពារសម្បត្តិវប្បធម៌ ក្នុងគ្រាមានជម្លោះប្រដាប់អាវុធ ធ្វើនៅទីក្រុងឡាអេ នាថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៥៤ និងដោយគូសបញ្ជាក់ពីភាពចាំបាច់ក្នុងការបំពេញបន្ថែមបទប្បញ្ញត្តិនានា តាមរយៈវិធានការទាំងឡាយសម្រាប់ពង្រឹងការអនុវត្តបទប្បញ្ញត្តិទាំងនេះ

ដោយមានបំណង ផ្តល់ជូនភាគីហត្ថលេខីនៃអនុសញ្ញានូវលទ្ធភាពចូលរួមយ៉ាងសកម្ម ក្នុងការការពារសម្បត្តិវប្បធម៌ក្នុងគ្រាមានជម្លោះប្រដាប់អាវុធ តាមរយៈការបង្កើតនីតិវិធីសមស្របនានា

ដោយយល់ឃើញថា វិធានទាំងឡាយដែលគ្រប់គ្រងការការពារសម្បត្តិវប្បធម៌ក្នុងគ្រាមានជម្លោះប្រដាប់អាវុធ ត្រូវឆ្លុះបញ្ចាំងពីការវិវត្តនៅក្នុងច្បាប់អន្តរជាតិ

ដោយអះអាងថា វិធានទាំងឡាយនៃច្បាប់អន្តរជាតិនឹងបន្តគ្រប់ដណ្តប់រាល់បញ្ហា ដែលមិនស្ថិតក្រោមបទប្បញ្ញត្តិនៃពិធីសារនេះ:

បានព្រមព្រៀងដូចតទៅ ៖

## ជំពូកទី ១
## សេចក្តីផ្តើម

មាត្រា ១.- និយមន័យ

គោលបំណងនៃពិធីសារនេះគឺ ៖

ក- "ភាគី" មានន័យថា រដ្ឋភាគីនៃពិធីសារនេះ

ខ- "សម្បត្តិវប្បធម៌" មានន័យថា សម្បត្តិវប្បធម៌ដែលត្រូវបានកំណត់នៅក្នុងមាត្រា ១នៃអនុសញ្ញា

គ- "អនុសញ្ញា" មានន័យថា អនុសញ្ញាស្តីពីការការពារសម្បត្តិវប្បធម៌ក្នុងគ្រាមានជម្លោះប្រដាប់អាវុធ ធ្វើនៅទីក្រុងឡាអេ នាថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៥៤

ឃ- "ភាគីហត្ថលេខី" មានន័យថា រដ្ឋភាគីនៃអនុសញ្ញា

ង- "ការការពារកម្រិតខ្ពស់" មានន័យថា ប្រព័ន្ធនៃការការពារកម្រិតខ្ពស់ ដូចមានចែងក្នុងមាត្រា១ និង១១

ច- "គោលដៅយោធា" មានន័យថា វត្ថុមួយដែលតាមរយៈប្រភេទ ទីតាំង គោលបំណង ឬការប្រើប្រាស់របស់ខ្លួនអាចរួមចំណែកយ៉ាងមានប្រសិទ្ធភាពចំពោះសកម្មភាពយោធា និងការបំផ្លាញទាំងស្រុង ឬ

ដោយផ្នែក ការកាន់កាប់ ឬការបង្ក្រាបទៅតាមកាលៈទេសៈដែលកើតឡើងនៅពេលនោះ ដែលផ្តល់នូវសារៈប្រយោជន៍ជាច់ខាតផ្នែកយោធា

ឆ- "ខុសច្បាប់" មានន័យថា ស្ថិតក្រោមការបង្ខិតបង្ខំ ឬមានន័យម្យ៉ាងទៀតថា ការរំលោភលើវិធានជាធរមានរបស់ច្បាប់ជាតិនៃទឹកដីស្ថិតក្រោមការកាន់កាប់ដោយយោធាបរទេស ឬច្បាប់អន្តរជាតិ

ជ- "បញ្ជី" មានន័យថា បញ្ជីអន្តរជាតិនៃសម្បត្តិវប្បធម៌ដែលស្ថិតក្រោមការការពារកម្រិតខ្ពស់ ដូចមានចែងនៅក្នុងមាត្រា ២៧ អនុកថាខ័ណ្ឌ ១ (ខ)

ឈ- "អគ្គនាយក" មានន័យថា អគ្គនាយកអង្គការយូណេស្កូ

ញ- "យូណេស្កូ" មានន័យថា អង្គការសហប្រជាជាតិសម្រាប់ការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌

ដ- "ពិធីសារទី១" មានន័យថា ពិធីសារស្តីពីការការពារសម្បត្តិវប្បធម៌ក្នុងគ្រាមានជម្លោះប្រដាប់អាវុធ ធ្វើនៅទីក្រុងឡាអេ នាថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៥៤។

មាត្រា ២.- ទំនាក់ទំនងជាមួយអនុសញ្ញា

ពិធីសារនេះបំពេញបន្ថែមទៅលើអនុសញ្ញា ក្នុងទំនាក់ទំនងគ្នារវាងរដ្ឋភាគីនានា។

មាត្រា ៣.- វិសាលភាពនៃការអនុវត្ត

១- បន្ថែមទៅលើបទប្បញ្ញត្តិទាំងឡាយ ដែលត្រូវអនុវត្តក្នុងគ្រាមានសន្តិភាព ពិធីសារនេះត្រូវអនុវត្តនៅក្នុងស្ថានភាពដូចមានចែងនៅក្នុងមាត្រា ១៨ កថាខ័ណ្ឌទី ១ និង២ នៃអនុសញ្ញា និងមាត្រា ២២ កថាខ័ណ្ឌទី ១។

២- ពេលណាដែលភាគីមួយក្នុងចំណោមភាគីទាំងឡាយនៃជម្លោះប្រដាប់អាវុធ មិនជាប់កាតព្វកិច្ចចំពោះពិធីសារនេះក៏ដោយ ក៏រដ្ឋភាគីទាំងឡាយនៃពិធីសារនេះនៅតែបន្តមានកាតព្វកិច្ចអនុវត្តន៍តាមពិធីសារនេះ នៅក្នុងទំនាក់ទំនងគ្នាទៅវិញទៅមករបស់ពួកគេ។ លើសពីនេះទៅទៀត ពួកគេកាន់តែត្រូវអនុវត្តតាមពិធីសារនេះ ទាក់ទងទៅនឹងរដ្ឋភាគីនៃជម្លោះ ដែលមិនមានជាប់កាតព្វកិច្ចតាមពិធីសារនេះ ប្រសិនបើភាគីនោះសុខចិត្តទទួលយក និងអនុវត្តតាមបទប្បញ្ញត្តិទាំងឡាយនៃពិធីសារនេះ។

មាត្រា ៤.- ទំនាក់ទំនងរវាងជំពូកទី ៣ និងបទប្បញ្ញត្តិផ្សេងៗរបស់អនុសញ្ញា និងពិធីសារ

ការអនុវត្តបទប្បញ្ញត្តិទាំងឡាយក្នុងជំពូកទី៣ នៃពិធីសារនេះ មិនត្រូវប៉ះពាល់ដល់ ៖

ក- ការអនុវត្តបទប្បញ្ញត្តិទាំងឡាយក្នុងជំពូកទី១ នៃអនុសញ្ញា និងជំពូកទី២ នៃពិធីសារនេះ។

ខ- ការអនុវត្តបទប្បញ្ញត្តិទាំងឡាយក្នុងជំពូកទី ២ នៃអនុសញ្ញា ក៏ដូចជាជួយដល់ការអនុវត្តរវាងភាគីទាំងឡាយនៃពិធីសារនេះ ឬរវាងភាគីមួយនិងរដ្ឋមួយដែលសុខចិត្តទទួលយក និងអនុវត្តតាមពិធីសារនេះស្របតាមមាត្រា ៣ វាក្យខ័ណ្ឌ ២ ដែលទីណាមានសម្បត្តិវប្បធម៌ត្រូវបានផ្តល់ជូនទាំងការការពារពិសេស និងការការពារកម្រិតខ្ពស់នោះ គឺមានតែបទប្បញ្ញត្តិនៃការការពារកម្រិតខ្ពស់ប៉ុណ្ណោះដែលត្រូវយកមកអនុវត្ត។

## ជំពូកទី ២
## បទប្បញ្ញត្តិទូទៅស្តីពីការការពារ

មាត្រា ៥.- ការការពារសម្បត្តិវប្បធម៌

យោងតាមមាត្រា ៣ នៃអនុសញ្ញា ត្រូវដាក់បញ្ចូលនូវវិធានការត្រៀមទាំងឡាយ ដែលរៀបចំឡើងនៅក្នុងគ្រាមានសន្តិភាព សម្រាប់ការការពារសម្បត្តិវប្បធម៌ទល់នឹងផលប៉ះពាល់នៃជម្លោះប្រដាប់អាវុធ រួមមាន

ការរៀបចំបញ្ជីសារពើភណ្ឌ ការធ្វើផែនការក្នុងគ្រាមានអាសន្នសម្រាប់ការពារទល់នឹងអគ្គីភ័យ ឬការដួលរលំរចនាសម្ព័ន្ធ ការត្រៀមរៀបចំយកចេញនូវចលនៈសម្បត្តិវប្បធម៌ ឬការផ្តល់ការការពារគ្រប់គ្រាន់នៅនឹងកន្លែងសម្បត្តិវប្បធម៌ និងការចាត់តាំងអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកការគាំពារសម្បត្តិវប្បធម៌។

មាត្រា ៦.- ការគោរពចំពោះសម្បត្តិវប្បធម៌

ក្នុងគោលបំណងធានានូវការគោរពចំពោះសម្បត្តិវប្បធម៌ ស្របតាមមាត្រា ៤ នៃអនុសញ្ញា ៖

ក- យោងតាមមាត្រា ៤ វាក្យខ័ណ្ឌ ២ នៃអនុសញ្ញា បដិប្បញ្ញត្តិដោយផ្អែកលើភាពចាំបាច់ដាច់ខាតផ្នែកយោធា អាចអនុវត្តបានដើម្បីធ្វើសកម្មភាពប្រទូសរាយមួយប្រឆាំងនឹងសម្បត្តិវប្បធម៌ តែនៅពេលណាដែល និងល្គឹកណាតែ ៖

(១) សម្បត្តិវប្បធម៌នោះតាមមុខងាររបស់វា ត្រូវបានបង្កើតឡើងបម្រើឲ្យគោលដៅយោធា និង

(២) គ្មានជម្រើសណាផ្សេងដែលអាចប្រើបាន ដើម្បីទទួលបានផលប្រយោជន៍ខាងយោធា ដូចគ្នានឹងធ្វើសកម្មភាពប្រទូសរាយខាងយោធាប្រឆាំងនឹងគោលដៅនោះ។

ខ- យោងតាមមាត្រា៤ វាក្យខ័ណ្ឌ២នៃអនុសញ្ញា បដិប្បញ្ញត្តិដោយផ្អែកលើភាពចាំបាច់ដាច់ខាតផ្នែកយោធា អាចត្រូវបានអនុវត្តដើម្បីប្រើប្រាស់សម្បត្តិវប្បធម៌ ក្នុងគោលបំណងទាំងឡាយជាហេតុធ្វើឱ្យសម្បត្តិវប្បធម៌នោះប្រឈមនឹងការបំផ្លាញ ឬការខូចខាត នៅពេលដែល និងដរាបណាគ្មានជម្រើសណាមួយដែលអាចប្រើបានរវាងការប្រើប្រាស់បែបនេះទៅលើសម្បត្តិវប្បធម៌ និងវិធីសាស្ត្រផ្សេងទៀតមកជំនួស ដើម្បីទទួលបានផលប្រយោជន៍ផ្នែកយោធាដូចគ្នា។

គ- មានតែនាយទាហានដែលបញ្ជាកម្លាំងទ័ពមានទំហំស្មើនឹងកងវរៈសេនាតូច ឬធំជាងនេះ ឬក៏កម្លាំងទ័ពដែលមានចំនួនតិចជាង នៅពេលកាលៈទេសៈមិនតម្រូវឱ្យមានដូច្នេះ ទើបអាចសម្រេចលើកយកហេតុផលនៃភាពចាំបាច់ដាច់ខាតផ្នែកយោធាមកអនុវត្តបាន។

ឃ- ក្នុងករណីផ្ទុះអាវុធ ដោយផ្អែកលើការសម្រេចចិត្ត ស្របតាមអនុវាក្យខ័ណ្ឌ (ក) សេចក្តីប្រកាសឲ្យប្រុងប្រយ័ត្នទុកជាមុនត្រូវតែធ្វើឡើង ពេលដែលកាលៈទេសៈអនុគ្រោះ។

មាត្រា ៧.- ការប្រុងប្រយ័ត្នក្នុងការវាយប្រហារ

ដោយមិនធ្វើឱ្យប៉ះពាល់ដល់ការប្រុងប្រយ័ត្នផ្សេងទៀត ដែលកំណត់ដោយច្បាប់មនុស្សធម៌អន្តរជាតិនៅក្នុងការធ្វើប្រតិបត្តិការយោធានោះ ភាគីនីមួយៗនៃជម្លោះត្រូវ ៖

ក- ធ្វើអ្វីៗទាំងអស់តាមដែលអាចធ្វើបាន ដើម្បីផ្ទៀងផ្ទាត់ថា គោលដៅទាំងឡាយដែលត្រូវវាយប្រហារ មិនមែនជាសម្បត្តិវប្បធម៌ដែលត្រូវបានការពារក្រោមមាត្រា ៤ នៃអនុសញ្ញា

ខ- ធ្វើការប្រុងប្រយ័ត្នគ្រប់យ៉ាងដែលអាចធ្វើបាន ក្នុងការជ្រើសរើសមធ្យោបាយ និងវិធីសាស្ត្រនៃការវាយប្រហារដោយចៀសវាងនិងក្នុងគ្រប់ករណីទាំងអស់ ដើម្បីកាត់បន្ថយការខូចខាតដោយចៃដន្យចំពោះសម្បត្តិវប្បធម៌ដែលត្រូវបានការពារក្រោមមាត្រា ៤ នៃអនុសញ្ញា

គ- មិនសម្រេចបើកការវាយប្រហារណាមួយ ដែលអាចបណ្តាលឱ្យមានការខូចខាតដោយចៃដន្យចំពោះសម្បត្តិវប្បធម៌ដែលត្រូវបានការពារក្រោមមាត្រា ៤ នៃអនុសញ្ញា ដែលអាចមានទំហំច្រើនលើសលប់បើធៀបទៅនឹងផលប្រយោជន៍ខាងយោធាជាក់ស្តែង និងដោយផ្ទាល់ ដូចដែលបានគិតទុកជាមុន

ឃ- លុបចោល ឬបញ្ឈប់ការវាយប្រហារជាបណ្តោះអាសន្ន ប្រសិនបើឃើញថា ៖

(១) គោលដៅនោះគឺជាសម្បត្តិវប្បធម៌ដែលត្រូវបានការពារក្រោមមាត្រា ៤ នៃអនុសញ្ញា

(ខ) រំពឹងទុកជាមុនថា ការវាយប្រហារនោះនឹងបណ្តាលឱ្យមានការខូចខាតដោយចៃដន្យទៅលើសម្បត្តិវប្បធម៌ដែលត្រូវបានការពារក្រោមមាត្រា ៤ នៃអនុសញ្ញា ដែលអាចមានទំហំច្រើនលើសលប់ ធៀបនឹងផលប្រយោជន៍ផ្នែកយោធាជាក់ស្តែងដែលទទួលបាន។

មាត្រា ៨.- ការប្រុងប្រយ័ត្នចំពោះផលវិបាកនៃភាពប្រទូសរ៉ាយ

ភាគីទាំងឡាយនៃជម្លោះត្រូវខិតខំឱ្យអស់លទ្ធភាពដែលអាចធ្វើបាន ដើម្បី៖

ក- យកចលនៈសម្បត្តិវប្បធម៌ចេញឱ្យឆ្ងាយពីបរិវេណជិតគោលដៅយោធា ឬផ្តល់ការការពារពេញលេញនៅនឹងកន្លែង

ខ- ចៀសវាងដាក់ទីតាំងគោលដៅយោធានៅជិតសម្បត្តិវប្បធម៌។

មាត្រា ៩.- ការការពារសម្បត្តិវប្បធម៌នៅក្នុងទឹកដីដែលកាន់កាប់ដោយយោធាបរទេស

១- ដោយមិនធ្វើឲ្យប៉ះពាល់ដល់បទប្បញ្ញត្តិនៃមាត្រា ៤ និង៥ នៃអនុសញ្ញា ភាគីមួយដែលកាន់កាប់ទាំងស្រុង ឬដោយផ្នែកលើទឹកដីរបស់ភាគីមួយទៀត ត្រូវហាមឃាត់និងទប់ស្កាត់ទាក់ទងទៅនឹងទឹកដីក្រោមការកាន់កាប់ដោយយោធាបរទេស នូវ៖

ក- ការនាំចេញណាមួយដោយខុសច្បាប់ ការផ្លាស់ទី ឬការផ្ទេរកម្មសិទ្ធិសម្បត្តិវប្បធម៌ផ្សេងទៀត

ខ- ការធ្វើកំណាយបុរាណវិទ្យា លើកលែងតែទីនោះមិនមានការកំណត់តឹងតែង ដើម្បីថែរក្សា ចុះបញ្ជី ឬអភិរក្សសម្បត្តិវប្បធម៌

គ- ការកែប្រែ ឬផ្លាស់ប្តូរការប្រើប្រាស់សម្បត្តិវប្បធម៌ ក្នុងគោលបំណងលាក់បំបាំង ឬបំផ្លាញភ័ស្តុតាងផ្នែកវប្បធម៌ ប្រវត្តិសាស្ត្រ ឬវិទ្យាសាស្ត្រ។

២- ប្រសិនបើកាលៈទេសៈមិនអនុញ្ញាតនោះទេ ការធ្វើកំណាយបុរាណវិទ្យា ការកែប្រែ ឬការផ្លាស់ប្តូរការប្រើប្រាស់សម្បត្តិវប្បធម៌នៅក្នុងទឹកដីក្រោមការកាន់កាប់ដោយយោធាបរទេស ត្រូវធ្វើឡើងដោយមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរមានសមត្ថកិច្ចជាតិនៃទឹកដីនោះ។

## ជំពូកទី ៣
## ការការពារកម្រិតខ្ពស់

មាត្រា ១០.- ការការពារកម្រិតខ្ពស់

សម្បត្តិវប្បធម៌អាចត្រូវដាក់នៅក្រោមការការពារកម្រិតខ្ពស់ ប្រសិនបើសម្បត្តិវប្បធម៌នោះឆ្លើយតបទៅតាមលក្ខខណ្ឌបីយ៉ាងដូចខាងក្រោម៖

ក- ជាសម្បត្តិវប្បធម៌ដែលមានសារៈសំខាន់បំផុតរបស់មនុស្សជាតិ

ខ- ត្រូវបានការពារដោយវិធានការច្បាប់ និងរដ្ឋបាលក្នុងស្រុក ដែលទទួលស្គាល់នូវតម្លៃវប្បធម៌ និងប្រវត្តិសាស្ត្រវិសេសវិសាលរបស់សម្បត្តិនោះ និងធានានូវការការពារកម្រិតខ្ពស់បំផុត

គ- មិនត្រូវបានប្រើប្រាស់សម្រាប់គោលបំណងយោធា ឬដើម្បីបិទបាំងទីតាំងយោធា និងចេញសេចក្តីប្រកាសជូនដំណឹងដោយភាគីកាន់កាប់លើសម្បត្តិវប្បធម៌នោះ ដែលអះអាងថាសម្បត្តិវប្បធម៌នោះនឹងមិនត្រូវបានប្រើប្រាស់សម្រាប់គោលបំណងយោធាឡើយ។

មាត្រា ១១.- ការផ្តល់ជូននូវការការពារកម្រិតខ្ពស់

១- រដ្ឋភាគីនីមួយៗត្រូវដាក់ជូនទៅគណៈកម្មាធិការ នូវបញ្ជីសម្បត្តិវប្បធម៌ដែលខ្លួនមានបំណងស្នើសុំ

ការផ្តល់ជូននូវការការពារកម្រិតខ្ពស់។

២- រដ្ឋភាគីដែលមានយុត្តាធិការ ឬការគ្រប់គ្រងលើសម្បត្តិវប្បធម៌ អាចស្នើសុំឲ្យដាក់សម្បត្តិវប្បធម៌នេះទៅក្នុងបញ្ជីដែលបង្កើតឡើងស្របតាមមាត្រា ២៧ អនុវាក្យខណ្ឌ ១ (ខ)។ សំណើនេះ ត្រូវដាក់បញ្ចូលនូវរាល់ព័ត៌មានចាំបាច់នានាដែលពាក់ព័ន្ធនឹងលក្ខណៈវិនិច្ឆ័យ ដូចមានចែងក្នុងមាត្រា ១០។ គណៈកម្មាធិការអាចអញ្ជើញឲ្យរដ្ឋភាគីមួយស្នើសុំបញ្ចូលសម្បត្តិវប្បធម៌ទៅក្នុងបញ្ជី។

៣- ភាគីផ្សេងទៀតដូចជា គណៈកម្មាធិការអន្តរជាតិសម្រាប់ស្លាកសញ្ញាខៀវ (International Committee of the Blue Shield) និងអង្គការក្រៅរដ្ឋាភិបាលផ្សេងទៀតដែលមានជំនាញពាក់ព័ន្ធ អាចផ្តល់អនុសាសន៍អំពីសម្បត្តិវប្បធម៌ជាក់លាក់ណាមួយចំពោះគណៈកម្មាធិការ។ ក្នុងករណីបែបនេះ គណៈកម្មាធិការអាចសម្រេចអញ្ជើញឲ្យរដ្ឋភាគីលើកសំណើបញ្ចូលសម្បត្តិវប្បធម៌នោះទៅក្នុងបញ្ជី។

៤- គ្មានសំណើសុំបញ្ចូលសម្បត្តិវប្បធម៌ដែលស្ថិតនៅក្នុងទឹកដីមួយ ក្រោមអធិបតេយ្យភាព ឬយុត្តាធិការដែលទាមទារដោយរដ្ឋលើសពីមួយ ហើយគ្មានការបញ្ចូលសម្បត្តិវប្បធម៌ណាមួយ ធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ភាគីទាំងឡាយនៃជម្លោះឡើយ ទោះក្នុងរូបភាពណាក៏ដោយ។

៥- នៅពេលទទួលបានសំណើសុំបញ្ចូលទៅក្នុងបញ្ជី គណៈកម្មាធិការត្រូវជូនព័ត៌មានដល់គ្រប់ភាគីទាំងអស់ដែលបានស្នើសុំ។ ភាគីទាំងអស់អាចដាក់ជូនគណៈកម្មាធិការនូវសំណើចុះបញ្ជី ក្នុងរយៈពេល៦០ថ្ងៃ។ សំណើទាំងនេះត្រូវធ្វើឡើងដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ ដូចមានចែងក្នុងមាត្រា ១០ តែប៉ុណ្ណោះ។ សំណើទាំងនេះត្រូវមានភាពជាក់លាក់ និងពាក់ព័ន្ធទៅនឹងអង្គហេតុ។ គណៈកម្មាធិការត្រូវពិចារណាលើសំណើទាំងនេះ ដោយផ្តល់ឲ្យភាគីស្នើសុំនូវឱកាសសមស្របដើម្បីឆ្លើយតប មុនឈានដល់ការសម្រេចចិត្ត។ បើទោះជាមានកំណត់ដោយមាត្រា ២៦ ក៏ដោយ ក៏នៅពេលដែលសំណើទាំងនេះដាក់ជូនមកដល់ហើយ គណៈកម្មាធិការត្រូវធ្វើការសម្រេចបញ្ចូលទៅក្នុងបញ្ជីដោយសំឡេងភាគច្រើន បួនភាគប្រាំនៃសមាជិកទាំងអស់ដែលមានវត្តមាន និងបានបោះឆ្នោត។

៦- ក្នុងការសម្រេចលើសំណើមួយ គណៈកម្មាធិការគួរសុំយោបល់ពីអង្គការរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងអ្នកជំនាញម្នាក់ៗ។

៧- ការសម្រេចផ្តល់ជូន ឬបដិសេធមិនផ្តល់ជូននូវការការពារកម្រិតខ្ពស់ អាចធ្វើឡើងបានទៅតាមលក្ខណៈវិនិច្ឆ័យដូចមានចែងក្នុងមាត្រា ១០ តែប៉ុណ្ណោះ។

៨- មានករណីលើកលែង នៅពេលដែលគណៈកម្មាធិការបានសន្និដ្ឋានថា ភាគីស្នើសុំបញ្ចូលសម្បត្តិវប្បធម៌ទៅក្នុងបញ្ជី មិនអាចបំពេញទៅតាមលក្ខណៈវិនិច្ឆ័យ ដូចមានចែងក្នុងមាត្រា ១០ អនុវាក្យខណ្ឌ (ខ) ក៏គណៈកម្មាធិការអាចសម្រេចផ្តល់ជូននូវការការពារកម្រិតខ្ពស់បានដែរ ឲ្យតែភាគីនោះដាក់ស្នើសុំជំនួយអន្តរជាតិ ដោយអនុលោមតាមមាត្រា ៣២។

៩- នៅពេលកើតមានភាពប្រទូសរ៉ាយ និងដោយផ្អែកលើមូលដ្ឋានគ្រាមានអាសន្ន ភាគីមួយនៃជម្លោះអាចស្នើសុំនូវការការពារកម្រិតខ្ពស់ចំពោះសម្បត្តិវប្បធម៌ ដែលស្ថិតនៅក្នុងដែនយុត្តាធិការ ឬការគ្រប់គ្រងរបស់ខ្លួន តាមរយៈការបញ្ជូនសំណើសុំនេះទៅគណៈកម្មាធិការ។ គណៈកម្មាធិការត្រូវបញ្ជូនសំណើនេះជាបន្ទាន់ទៅគ្រប់ភាគីទាំងអស់នៃជម្លោះ។ នៅក្នុងករណីបែបនេះ គណៈកម្មាធិការនឹងពិចារណាលើភាពជាតំណាងពីភាគីពាក់ព័ន្ធទាំងឡាយឲ្យបានលឿន។ ការសម្រេចផ្តល់ជូននូវការការពារកម្រិតខ្ពស់ជាបណ្តោះអាសន្ន ត្រូវធ្វើភ្លាមដោយសំឡេងភាគច្រើន បួនភាគប្រាំនៃសមាជិកទាំងអស់ដែលមានវត្តមាន និងបានបោះឆ្នោតដោយមិនគិតពីមាត្រា ២៦។ ក្នុងពេលរង់ចាំលទ្ធផលនៃនីតិវិធីធម្មតាសម្រាប់ការផ្តល់ជូននូវការការពារ

កម្រិតខ្ពស់ គណៈកម្មាធិការអាចផ្ដល់ជូននូវការការពារកម្រិតខ្ពស់ជាបណ្ដោះអាសន្នបាន ឲ្យតែឆ្លើយតបទៅនឹងបទប្បញ្ញត្តិនៃមាត្រា ១០ អនុវាក្យខ័ណ្ឌ (ក)និង(គ)។

១០- គណៈកម្មាធិការត្រូវផ្ដល់ជូននូវការការពារកម្រិតខ្ពស់ដល់សម្បត្តិវប្បធម៌ ចាប់តាំងពីពេលដែលសម្បត្តិវប្បធម៌នេះចុះក្នុងបញ្ជី។

១១- អគ្គនាយកត្រូវជូនដំណឹងទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ និងទៅគ្រប់ភាគីទាំងអស់ដោយគ្មានពន្យារពេលអំពីសេចក្ដីសម្រេចណាមួយរបស់គណៈកម្មាធិការ ដែលបានបញ្ចូលសម្បត្តិវប្បធម៌ទៅក្នុងបញ្ជី។

### មាត្រា ១២.- អភ័យឯកសិទ្ធិនៃសម្បត្តិវប្បធម៌ ដែលស្ថិតក្រោមការការពារកម្រិតខ្ពស់

ភាគីទាំងឡាយនៃជម្លោះត្រូវធានាឲ្យបាននូវអភ័យឯកសិទ្ធិនៃសម្បត្តិវប្បធម៌ ដែលស្ថិតក្រោមការការពារកម្រិតខ្ពស់ តាមរយៈការមិនយកសម្បត្តិបែបនេះជាគោលដៅនៃការវាយប្រហារ ឬការមិនប្រើប្រាស់បែបណាមួយលើសម្បត្តិនេះ ឬតំបន់នៅជិតៗសម្បត្តិនេះ ដើម្បីគាំទ្រដល់សកម្មភាពយោធាឡើយ។

### មាត្រា ១៣.- ការបាត់បង់នូវការការពារកម្រិតខ្ពស់

១- សម្បត្តិវប្បធម៌ដែលស្ថិតក្រោមការការពារកម្រិតខ្ពស់ត្រូវបាត់បង់សិទ្ធិនេះ ប្រសិនបើ ៖

ក- ការការពារបែបនេះត្រូវបានព្យួរទុក ឬលុបចោលស្របតាមមាត្រា ១៤ ឬ

ខ- ប្រសិនបើ ឬនៅពេលណាដែលតាមការប្រើប្រាស់របស់វា សម្បត្តិនេះក្លាយជាគោលដៅយោធា។

២- នៅក្នុងស្ថានភាពដូចអនុវាក្យខ័ណ្ឌ ១(ខ) សម្បត្តិបែបនេះអាចក្លាយជាគោលដៅនៃការវាយប្រហារ តែក្នុងករណី ៖

ក- ការវាយប្រហារ គឺជាមធ្យោបាយតែមួយគត់ដែលអាចទៅរួច ក្នុងការបញ្ចប់ការប្រើប្រាស់សម្បត្តិវប្បធម៌ ដែលលើកឡើងក្នុងអនុវាក្យខ័ណ្ឌ ១ (ខ)

ខ- ធ្វើការប្រុងប្រយ័ត្នគ្រប់បែបយ៉ាងដែលអាចទៅរួច ក្នុងការជ្រើសរើសមធ្យោបាយ និងវិធីសាស្ត្រនៃការវាយប្រហារ ក្នុងគោលបំណងបញ្ចប់កាប្រើប្រាស់បែបនេះ និងចៀសវាង ឬកាត់បន្ថយទោះក្នុងករណីណាក៏ដោយ នូវការខូចខាតចំពោះសម្បត្តិវប្បធម៌

គ- ប្រសិនបើកាលៈទេសៈអនុញ្ញាត ដោយយោងទៅតាមការចាំបាច់នៃការការពារខ្លួនឯងភ្លាមៗនោះ៖

(១) ការវាយប្រហារត្រូវបានទទួលបញ្ជាពីបញ្ជាការប្រតិបត្តិការកម្រិតខ្ពស់បំផុត

(២) ផ្ដល់សញ្ញាព្រមានជាមុនប្រកបដោយប្រសិទ្ធភាពទៅដល់កងកម្លាំងបដិបក្ខ ដែលទាមទារឲ្យបញ្ចប់នូវការប្រើប្រាស់ ដូចមានលើកឡើងក្នុងអនុវាក្យខណ្ឌ១ (ខ)

(៣) ផ្ដល់ជូនពេលវេលាសមស្របទៅដល់កងកម្លាំងបដិបក្ខ ឲ្យកែប្រែស្ថានការណ៍ឡើងវិញ។

### មាត្រា ១៤.- ការព្យួរទុក និងការលុបចោលនូវការការពារកម្រិតខ្ពស់

១- នៅទីកន្លែងណាដែលសម្បត្តិវប្បធម៌លែងឆ្លើយតបទៅតាមលក្ខណៈវិនិច្ឆ័យណាមួយ ដូចមានចែងក្នុងមាត្រា ១០ នៃពិធីសារនេះ គណៈកម្មាធិការអាចព្យួរទុកនូវឋានៈនៃការការពារកម្រិតខ្ពស់របស់សម្បត្តិវប្បធម៌ ឬលុបចោលនូវឋានៈនោះ តាមរយៈការដកសម្បត្តិវប្បធម៌នោះចេញពីបញ្ជី។

២- ក្នុងករណីមានការរំលោភធ្ងន់ធ្ងរចំពោះមាត្រា ១២ ពាក់ព័ន្ធនឹងសម្បត្តិវប្បធម៌ស្ថិតក្រោមការការពារកម្រិតខ្ពស់ ដែលបណ្តាលមកពីការប្រើប្រាស់សម្បត្តិវប្បធម៌ ដើម្បីគាំទ្រដល់សកម្មភាពយោធា គណៈកម្មាធិការអាចព្យួរទុកនូវឋានៈនៃការការពារកម្រិតខ្ពស់។ នៅទីកន្លែងណាដែលមានការរំលោភបំពានបែបនេះនៅតែបន្ត គណៈកម្មាធិការអាចលុបចោលក្នុងករណីពិសេសនូវឋានៈនៃការការពារកម្រិតខ្ពស់ តាមរយៈការដកសម្បត្តិវប្បធម៌នេះចេញពីបញ្ជី។

៣- អគ្គនាយកត្រូវជូនដំណឹងដោយគ្មានពន្យារពេល ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ និងទៅគ្រប់ភាគីទាំងអស់នៃពិធីសារនេះ អំពីសេចក្តីសម្រេចណាមួយរបស់គណៈកម្មាធិការ ក្នុងការព្យួរទុក ឬលុបចោលនូវការការពារកម្រិតខ្ពស់របស់សម្បត្តិវប្បធម៌។

៤- មុនពេលធ្វើសេចក្តីសម្រេចចិត្តបែបនេះ គណៈកម្មាធិការត្រូវផ្តល់ឱកាសទៅគ្រប់ភាគីទាំងអស់ដើម្បីបញ្ចេញយោបល់របស់ពួកគេ។

## ជំពូកទី ៤
## ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ និងយុត្តាធិការ

មាត្រា ១៥.- ការរំលោភបំពានធ្ងន់ធ្ងរចំពោះពិធីសារនេះ

១- បុគ្គលណាមួយដែលប្រព្រឹត្តបទល្មើសនៅក្នុងអត្ថន័យនៃពិធីសារនេះ ប្រសិនបើបុគ្គលនោះមានចេតនារំលោភទៅលើអនុសញ្ញា ឬពិធីសារនេះ ដែលប្រព្រឹត្តនូវអំពើណាមួយដូចខាងក្រោម ៖

ក- ប្រែក្លាយសម្បត្តិវប្បធម៌ដែលស្ថិតក្រោមការការពារកម្រិតខ្ពស់ ឲ្យទៅជាគោលដៅនៃការវាយប្រហារ

ខ- ប្រើប្រាស់សម្បត្តិវប្បធម៌ដែលស្ថិតក្រោមការការពារកម្រិតខ្ពស់ ឬតំបន់នៅក្បែរៗនោះ ដើម្បីគាំទ្រដល់សកម្មភាពយោធា

គ- បំផ្លិចបំផ្លាញធំធេង ឬដកហូតយកមកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួននូវសម្បត្តិវប្បធម៌ ដែលស្ថិតក្រោមការការពារដោយអនុសញ្ញា និងពិធីសារនេះ

ឃ-ប្រែក្លាយសម្បត្តិវប្បធម៌ដែលស្ថិតក្រោមការការពារដោយអនុសញ្ញា និងពិធីសារនេះ ទៅជាគោលដៅនៃការវាយប្រហារ

ង- ចោរកម្ម អំពើលួចប្លន់ ឬការដកហូតយកដោយមិនត្រឹមត្រូវ ឬអំពើបំផ្លាញសំដៅប្រឆាំងលើសម្បត្តិវប្បធម៌ ដែលស្ថិតក្រោមការការពារដោយអនុសញ្ញា។

២- ភាគីនីមួយៗត្រូវប្រកាន់យកវិធានការនានាតាមការចាំបាច់ ដើម្បីកំណត់ជាបទល្មើសព្រហ្មទណ្ឌស្របតាមច្បាប់ជាតិរបស់ខ្លួននូវបទល្មើសទាំងឡាយដែលមានកំណត់នៅក្នុងមាត្រានេះ និងដាក់បទល្មើសទាំងនេះឲ្យទទួលទោសសមស្រប។ ក្នុងពេលកំពុងអនុវត្តដូច្នេះ ភាគីទាំងអស់ត្រូវអនុវត្តតាមគោលការណ៍ទូទៅនៃច្បាប់និងច្បាប់អន្តរជាតិ ដែលរួមមានទាំងវិធានទាំងឡាយដែលពង្រីកការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់បុគ្គល រហូតទៅដល់បុគ្គលទាំងឡាយក្រៅពីអ្នកដែលប្រព្រឹត្តអំពើផ្ទាល់។

មាត្រា ១៦.- យុត្តាធិការ

១- ដោយមិនធ្វើឲ្យប៉ះពាល់ដល់វាក្យខ័ណ្ឌ២ ភាគីនីមួយៗត្រូវចាត់វិធានការច្បាប់ចាំបាច់ ដើម្បីបង្កើតយុត្តាធិការរបស់ខ្លួនលើបទល្មើសទាំងឡាយ ដូចមានចែងក្នុងមាត្រា ១៥ នៅក្នុងករណីដូចខាងក្រោម ៖

ក- នៅពេលដែលបទល្មើសបែបនេះ ត្រូវបានប្រព្រឹត្តឡើងនៅក្នុងទឹកដីនៃរដ្ឋនោះ

ខ- នៅពេលដែលជនល្មើសដែលត្រូវចោទប្រកាន់ មានសញ្ជាតិរបស់រដ្ឋនោះ

គ- ក្នុងករណីនៃបទល្មើសទាំងឡាយដូចមានចែងក្នុងមាត្រា ១៥ អនុវាក្យខណ្ឌ (ក) ដល់ (គ) នៅពេលដែលជនល្មើសត្រូវចោទប្រកាន់ មានវត្តមាននៅក្នុងទឹកដីរបស់ខ្លួន។

២- ពាក់ព័ន្ធនឹងការអនុវត្តយុត្តាធិការ និងដោយមិនប៉ះពាល់ដល់មាត្រា ២៨ នៃអនុសញ្ញា ៖

ក- ពិធីសារនេះមិនរារាំងនូវការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គល ឬការអនុវត្តយុត្តាធិការតាមច្បាប់ជាតិ ឬអន្តរជាតិ ដែលអាចអនុវត្តបាន ឬប៉ះពាល់ដល់ការអនុវត្តយុត្តាធិការស្របតាមច្បាប់អន្តរជាតិតាមប្រពៃណីនោះឡើយ

ខ- លើកលែងតែក្នុងករណីដែលរដ្ឋមួយមិនមែនជាភាគីនៃពិធីសារនេះ អាចទទួលយក និងអនុវត្តបទប្បញ្ញត្តិទាំងឡាយនៃពិធីសារនេះ ស្របតាមមាត្រា ៣ វាក្យខណ្ឌ ២ ប៉ុណ្ណោះ ចំពោះសមាជិកនៃកងកម្លាំងប្រដាប់អាវុធ និងប្រជាជាតិនៃរដ្ឋមួយដែលមិនមែនជារដ្ឋភាគីនៃពិធីសារនេះ ដោយលើកលែងតែអ្នកទាំងនោះកំពុងបម្រើការងារនៅក្នុងកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋមួយដែលជាភាគីនៃពិធីសារនេះ គឺមិនទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលដូចមានចែងក្នុងពិធីសារនេះឡើយ ហើយពិធីសារនេះក៏មិនកំណត់ឲ្យមានកាតព្វកិច្ចដើម្បីបង្កើតឲ្យមានយុត្តាធិការលើបុគ្គលបែបនេះ ឬក៏ធ្វើបត្យាប័នពួកគេដែរ។

## មាត្រា ១៧.- ការកាត់ទោស

១- រដ្ឋដែលនៅក្នុងទឹកដីរបស់ខ្លួនត្រូវបានរកឃើញថា មានវត្តមានជនល្មើសដែលត្រូវចោទប្រកាន់ទៅលើបទល្មើសណាមួយ យោងតាមមាត្រា ១៥ អនុវាក្យខណ្ឌ ១ (ក) ដល់ (គ) ប្រសិនបើមិនធ្វើបត្យាប័នជននោះទេ រដ្ឋនោះត្រូវបញ្ជូនករណីនេះដោយគ្មានការលើកលែងអ្វីទាំងអស់ និងដោយគ្មានការពន្យារពេលមិនសមស្រប ទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ដើម្បីយកទៅកាត់ទោសទៅតាមនីតិវិធីដែលស្របតាមច្បាប់ជាតិរបស់ខ្លួន ឬទៅតាមវិធានពាក់ព័ន្ធទាំងឡាយនៃច្បាប់អន្តរជាតិ ប្រសិនបើមានជាធរមាន។

២- ដោយមិនធ្វើឲ្យប៉ះពាល់ដល់វិធានពាក់ព័ន្ធទាំងឡាយនៃច្បាប់អន្តរជាតិ ប្រសិនបើកំពុងអនុវត្តជាធរមាន បុគ្គលណាមួយដែលកំពុងស្ថិតក្នុងដំណើរការនៃរឿងក្តីពាក់ព័ន្ធនឹងអនុសញ្ញា ឬពិធីសារនេះ ត្រូវធានាឲ្យទទួលបាននីតិវិធីដោយយុត្តិធម៌ និងការកាត់ក្តីដោយយុត្តិធម៌ស្របទៅតាមច្បាប់ជាតិ និងច្បាប់អន្តរជាតិនៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការកាត់ក្តី ហើយក៏គ្មានករណីណាមួយដែលបុគ្គលបែបនេះទទួលបានការធានា ដែលមានការអនុគ្រោះតិចជាងការធានាទាំងឡាយ ដែលមានចែងនៅក្នុងច្បាប់អន្តរជាតិនោះឡើយ។

## មាត្រា ១៨.- ការធ្វើបត្យាប័ន

១- បទល្មើសទាំងឡាយដែលមានចែងក្នុងមាត្រា ១៥ អនុវាក្យខណ្ឌ ១ (ក) ដល់ (គ) ត្រូវចាត់ទុកថាបានបញ្ចូលជាបទល្មើសដែលអាចធ្វើបត្យាប័នបាននៅក្នុងសន្ធិសញ្ញាស្តីពីបត្យាប័នដែលមានជាធរមានរវាងភាគីណាមួយ នៅមុនពេលពិធីសារនេះចូលជាធរមាន។ ភាគីទាំងឡាយសន្យាថានឹងបញ្ចូលបទល្មើសបែបនេះទៅក្នុងសន្ធិសញ្ញាស្តីពីបត្យាប័ន ដែលនឹងត្រូវចុះហត្ថលេខារវាងភាគីទាំងនោះ។

២- នៅពេលដែលភាគីមួយដែលដាក់លក្ខខណ្ឌថា ការធ្វើបត្យាប័នទៅបានលុះត្រាតែមានសន្ធិសញ្ញាលើបត្យាប័នជាមួយភាគីមួយទៀតដែលខ្លួនមិនមានសន្ធិសញ្ញាស្តីពីបត្យាប័ននោះ ភាគីស្នើសុំដោយផ្អែកលើជម្រើសរបស់ខ្លួនផ្ទាល់ ចាត់ទុកពិធីសារនេះជាមូលដ្ឋានគតិយុត្តិមួយសម្រាប់ការធ្វើបត្យាប័នចំពោះបទល្មើសទាំងឡាយដូចមានចែងក្នុងមាត្រា ១៥ អនុវាក្យខណ្ឌ ១ (ក) ដល់ (គ)។

៣- ភាគីទាំងឡាយដែលមិនមានដាក់លក្ខខណ្ឌថា ការធ្វើបត្យាប័នទៅបានលុះត្រាតែមានសន្ធិសញ្ញា ត្រូវចាត់ទុកថាបទល្មើសទាំងឡាយដូចមានកំណត់ក្នុងមាត្រា ១៥ អនុវាក្យខ័ណ្ឌ ១(ក) ដល់(គ) ជាបទល្មើសដែលអាចធ្វើបត្យាប័នបានរវាងពួកគេ ដោយយោងតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់របស់ភាគីស្នើសុំ។

៤- ប្រសិនបើចាំបាច់ បទល្មើសទាំងឡាយដែលមានកំណត់នៅក្នុងមាត្រា ១៥ អនុវាក្យខ័ណ្ឌ ១ (ក) ដល់(គ) ត្រូវចាត់ទុកដូចជាបទល្មើសទាំងនេះបានប្រព្រឹត្តឡើង មិនត្រឹមតែនៅទីកន្លែងដែលបទល្មើសនោះកើតឡើងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនៅក្នុងទឹកដីរបស់ភាគីទាំងឡាយ ដែលបានបង្កើតយុត្តាធិការស្របតាមមាត្រា ១៦ វាក្យខ័ណ្ឌ ១ សម្រាប់បម្រើឲ្យគោលបំណងនៃការធ្វើបត្យាប័នរបស់ភាគីទាំងនោះ។

មាត្រា ១៩.- ជំនួយផ្នែកច្បាប់ទៅវិញទៅមក

១- ភាគីទាំងឡាយត្រូវផ្តល់ឲ្យគ្នាទៅវិញទៅមកនូវវិធានការខ្ពស់បំផុតនៃជំនួយ ពាក់ព័ន្ធនឹងការស៊ើបអង្កេត ឬឧក្រិដ្ឋជន ឬដំណើរការធ្វើបត្យាប័ន ដែលធ្វើឡើងចំពោះបទល្មើសដូចមានកំណត់នៅក្នុងមាត្រា ១៥ ដែលរួមមានទាំងជំនួយក្នុងការទទួលបានភ័ស្តុតាងដែលចាំបាច់សម្រាប់បម្រើឲ្យដំណើរការក្តី តាមមធ្យោបាយផ្ទាល់របស់ពួកគេ។

២- ភាគីទាំងឡាយត្រូវបំពេញភារកិច្ចរបស់ខ្លួន ដូចមានចែងក្នុងវាក្យខ័ណ្ឌ ១ ស្របទៅតាមសន្ធិសញ្ញា ឬកិច្ចព្រមព្រៀងទាំងឡាយស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមកដែលពួកគេអាចមាន។ ប្រសិនបើមិនមានសន្ធិសញ្ញាឬកិច្ចព្រមព្រៀងបែបនេះទេ ភាគីទាំងឡាយត្រូវផ្តល់ជំនួយឲ្យគ្នាទៅវិញទៅមក ដោយអនុលោមទៅតាមច្បាប់ជាតិរបស់ពួកគេ។

មាត្រា ២០.- មូលហេតុសម្រាប់បដិសេធ

១-សម្រាប់គោលបំណងនៃការធ្វើបត្យាប័ន ពោលគឺបទល្មើសទាំងឡាយដែលមានចែងក្នុងមាត្រា ១៥ អនុវាក្យខ័ណ្ឌ ១(ក) ដល់(គ) និងសម្រាប់គោលបំណងនៃការផ្តល់ជំនួយផ្លូវច្បាប់ទៅវិញទៅមក ពោលគឺបទល្មើសទាំងឡាយដូចមានចែងក្នុងមាត្រា ១៥ មិនត្រូវចាត់ទុកថាជាបទល្មើសនយោបាយ ឬជាបទល្មើសដែលពាក់ព័ន្ធនឹងបទល្មើសនយោបាយឬជាបទល្មើសដោយហេតុផលនយោបាយឡើយ។ ដូចគ្នានេះដែរ សំណើសុំធ្វើបត្យាប័ន ឬសុំជំនួយផ្នែកច្បាប់ទៅវិញទៅមក ដោយផ្អែកលើបទល្មើសបែបនេះ មិនអាចត្រូវបានបដិសេធដោយផ្អែកតែលើហេតុផលមួយគត់ថា វាមានពាក់ព័ន្ធនឹងបទល្មើសនយោបាយ ឬបទល្មើសមួយដែលពាក់ព័ន្ធនឹងបទល្មើសនយោបាយ ឬបទល្មើសមួយដែលត្រូវបានជម្រុញដោយហេតុផលនយោបាយនោះទេ។

២- នៅក្នុងពិធីសារនេះ គ្មានបទប្បញ្ញត្តិណាមួយដែលត្រូវបានបកស្រាយថា បានកំណត់កាតព្វកិច្ចឲ្យធ្វើបត្យាប័ន ឬឲ្យផ្តល់ជំនួយផ្នែកច្បាប់ទៅវិញទៅមកនោះទេ ប្រសិនបើភាគីទទួលសំណើ មានមូលហេតុធំធេងធ្វើឲ្យជឿថា សំណើសុំធ្វើបត្យាប័នសម្រាប់បទល្មើសទាំងឡាយដូចមានកំណត់នៅក្នុងមាត្រា ១៥ អនុវាក្យខ័ណ្ឌ ១ (ក) ដល់ (គ) ឬសម្រាប់សុំជំនួយផ្នែកច្បាប់ទៅវិញទៅមក ពាក់ព័ន្ធនឹងបទល្មើសទាំងឡាយដូចមានកំណត់នៅក្នុងមាត្រា ១៥ ត្រូវបានធ្វើឡើងសម្រាប់គោលបំណងនៃការកាត់ទោស ឬដាក់ទោសបុគ្គលម្នាក់ដោយផ្អែកលើជាតិសាសន៍ សាសនា សញ្ជាតិ ប្រភពកំណើត ឬគំនិតនយោបាយរបស់បុគ្គលនោះ ឬបើផ្តល់ជូនតាមសំណើនោះ នឹងបណ្តាលឲ្យខូចខាតដល់ឋានៈរបស់បុគ្គលនោះសម្រាប់ហេតុផលណាមួយ ក្នុងចំណោមហេតុផលទាំងនេះ។

មាត្រា ២១.- វិធានការពាក់ព័ន្ធនឹងការរំលោភបំពានផ្សេងទៀត

ដោយមិនប៉ះពាល់ដល់មាត្រា ២៨ នៃអនុសញ្ញា ភាគីនីមួយៗត្រូវអនុម័តយកនូវវិធានការច្បាប់ រដ្ឋបាល ឬវិន័យតាមការចាំបាច់ ដើម្បីបង្ក្រាបនូវរាល់អំពើដូចខាងក្រោមនៅពេលដែលបានប្រព្រឹត្តឡើងដោយចេតនា ៖

ក- ការប្រើប្រាស់ណាមួយលើសម្បត្តិវប្បធម៌ ដែលរំលោភលើអនុសញ្ញា ឬពិធីសារនេះ

ខ- ការនាំចេញណាមួយដោយខុសច្បាប់ ការយកចេញ ឬការផ្ទេរកម្មសិទ្ធិនៃសម្បត្តិវប្បធម៌ពីទឹកដីក្រោមការកាន់កាប់ដោយយោធាបរទេស ដោយរំលោភលើអនុសញ្ញា ឬពិធីសារនេះ។

## ជំពូកទី ៥
## ការការពារសម្បត្តិវប្បធម៌ ក្នុងគ្រាមានជម្លោះប្រដាប់អាវុធ ដែលមិនមានចរិតលក្ខណៈអន្តរជាតិ

មាត្រា ២២.- ជម្លោះប្រដាប់អាវុធដែលមិនមានចរិតលក្ខណៈអន្តរជាតិ

១- ពិធីសារនេះត្រូវអនុវត្តនៅក្នុងគ្រាមានជម្លោះប្រដាប់អាវុធ ដែលមិនមានចរិតលក្ខណៈអន្តរជាតិ ដែលកើតឡើងនៅក្នុងទឹកដីរបស់ភាគីមួយនៃភាគីទាំងឡាយ។

២- ពិធីសារនេះមិនត្រូវអនុវត្តចំពោះស្ថានភាពនៃភាពចលាចល ឬភាពតានតឹងក្នុងស្រុក ដូចជា អំពើកុបកម្ម និងអំពើហិង្សាដាច់ដោយឡែកនិងម្តងម្កាល និងអំពើផ្សេងទៀតដែលមានភាពស្រដៀងគ្នា។

៣- នៅក្នុងពិធីសារនេះ គ្មានបទប្បញ្ញត្តិណាមួយត្រូវបានលើកជាសំអាងមកប្រើប្រាស់ ទោះជាតាមគ្រប់មធ្យោបាយស្របច្បាប់ក៏ដោយ ក្នុងគោលបំណងធ្វើឲ្យប៉ះពាល់ដល់អធិបតេយ្យភាពរបស់រដ្ឋមួយ ឬការទទួលខុសត្រូវរបស់រដ្ឋាភិបាលនោះ ដើម្បីថែរក្សា ឬបង្កើតច្បាប់ និងសណ្តាប់ធ្នាប់ឡើងវិញនៅក្នុងរដ្ឋនោះ ឬក៏ដើម្បីការពារ ឯកភាពជាតិ និងបូរណភាពដែនដីរបស់រដ្ឋនោះឡើយ។

៤- នៅក្នុងពិធីសារនេះ គ្មានបទប្បញ្ញត្តិណាមួយត្រូវប៉ះពាល់ដល់យុត្តាធិការជាចម្បងរបស់ភាគីមួយលើការរំលោភបំពានទាំងឡាយដូចមានចែងក្នុងមាត្រា ១៥ ដែលនៅក្នុងទឹកដីរបស់ភាគីនោះមានកើតឡើងនូវជម្លោះប្រដាប់អាវុធដែលមិនមានចរិតលក្ខណៈអន្តរជាតិឡើយ។

៥- នៅក្នុងពិធីសារនេះ គ្មានបទប្បញ្ញត្តិណាមួយត្រូវបានលើកជាសំអាងមកប្រើប្រាស់ជាយុត្តិកម្មសម្រាប់ការធ្វើអន្តរាគមន៍ដោយផ្ទាល់ឬដោយប្រយោល ទោះសម្រាប់ហេតុផលណាមួយក៏ដោយនៅក្នុងជម្លោះប្រដាប់អាវុធ ឬនៅក្នុងកិច្ចការផ្ទៃក្នុង ឬអន្តរជាតិរបស់ភាគី នៅក្នុងទឹកដីដែលជម្លោះកើតឡើងនោះឡើយ។

៦- ការអនុវត្តពិធីសារនេះចំពោះស្ថានភាពដែលត្រូវបានលើកឡើងនៅក្នុងវាក្យខណ្ឌទី ១ មិនត្រូវប៉ះពាល់ដល់ឋានៈស្របច្បាប់របស់ភាគីទាំងឡាយនៃជម្លោះឡើយ។

៧- អង្គការយូណេស្កូអាចផ្តល់សេវារបស់ខ្លួនដល់ភាគីទាំងឡាយនៃជម្លោះ។

## ជំពូកទី ៦
## និដ្ឋភាពស្ថាប័ន

មាត្រា ២៣.- កិច្ចប្រជុំរបស់រដ្ឋភាគី

១- កិច្ចប្រជុំរបស់រដ្ឋភាគីត្រូវរៀបចំឡើងនៅចំពេលមហាសន្និបាតអង្គការយូណេស្កូ និងក្នុងកិច្ចសម្របសម្រួលជាមួយកិច្ចប្រជុំរបស់ភាគីហត្ថលេខី ប្រសិនបើកិច្ចប្រជុំបែបនេះត្រូវបានស្នើឡើងដោយអគ្គនាយកអង្គការយូណេស្កូ។

២- កិច្ចប្រជុំរបស់រដ្ឋភាគីត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។

៣- កិច្ចប្រជុំរបស់រដ្ឋភាគីត្រូវមានមុខងារដូចតទៅ ៖

(ក) បោះឆ្នោតជ្រើសរើសសមាជិករបស់គណៈកម្មាធិការស្របទៅតាមមាត្រា ២៤ វាក្យខ័ណ្ឌ ១

(ខ) អនុម័តគោលការណ៍ណែនាំ ដែលរៀបចំឡើងដោយគណៈកម្មាធិការ ស្របទៅតាមមាត្រា ២៧ អនុវាក្យខ័ណ្ឌ ១ (ក)

(គ) ផ្តល់ការណែនាំ និងត្រួតពិនិត្យការប្រើប្រាស់មូលនិធិរបស់គណៈកម្មាធិការ

(ឃ) ពិនិត្យលើរបាយការណ៍ដែលគណៈកម្មាធិការបានដាក់ជូន ស្របតាមមាត្រា ២៧ អនុវាក្យខ័ណ្ឌ ១ (ឃ)

(ង) ពិភាក្សាលើបញ្ហាណាមួយដែលទាក់ទងនឹងការអនុវត្តពិធីសារនេះ និងលើកជាអនុសាសន៍តាមការចាំបាច់។

៤- យោងតាមសំណើយ៉ាងហោចណាស់មួយភាគប្រាំនៃភាគីទាំងអស់ អគ្គនាយកអង្គការយូណេស្កូត្រូវកោះប្រជុំវិសាមញ្ញរបស់រដ្ឋភាគី។

មាត្រា ២៤.- គណៈកម្មាធិការសម្រាប់ការការពារសម្បត្តិវប្បធម៌ក្នុងគ្រាមានជម្លោះប្រដាប់អាវុធ

១- គណៈកម្មាធិការសម្រាប់ការការពារសម្បត្តិវប្បធម៌ក្នុងគ្រាមានជម្លោះប្រដាប់អាវុធ ត្រូវបានបង្កើតឡើងតាមស្មារតីនៃពិធីសារនេះ។ គណៈកម្មាធិការនេះត្រូវមានសមាសភាព ១២ រដ្ឋភាគី ដែលត្រូវបោះឆ្នោតជ្រើសតាំងដោយកិច្ចប្រជុំរបស់រដ្ឋភាគី។

២- គណៈកម្មាធិការត្រូវជួបគ្នាក្នុងមួយឆ្នាំម្តង ក្នុងសម័យប្រជុំសាមញ្ញ និងក្នុងសម័យប្រជុំវិសាមញ្ញច្រើនដងតាមការចាំបាច់។

៣- ក្នុងការកំណត់សមាជិកភាពរបស់គណៈកម្មាធិការ រដ្ឋភាគីត្រូវខិតខំធានាឲ្យបាននូវភាពជាតំណាងប្រកបដោយសមធម៌ពីតំបន់ និងវប្បធម៌ផ្សេងៗគ្នានៃពិភពលោក។

៤- ភាគីដែលជាសមាជិករបស់គណៈកម្មាធិការ ត្រូវជ្រើសរើសជាតំណាងរបស់ពួកគេ នូវបុគ្គលដែលមានលក្ខណៈសម្បត្តិនៅក្នុងវិស័យបេតិកភណ្ឌវប្បធម៌ ការពារជាតិ ឬច្បាប់អន្តរជាតិ ហើយសមាជិកទាំងអស់ត្រូវខិតខំប្រឹងប្រែង ដោយពិគ្រោះយោបល់ជាមួយគ្នាទៅវិញទៅមកដើម្បីធានាថា គណៈកម្មាធិការទាំងមូលមានជំនាញគ្រប់គ្រាន់នៅក្នុងវិស័យទាំងនេះ។

មាត្រា ២៥.- អាណត្តិ

១- រដ្ឋភាគីមួយជាប់ឆ្នោតនៅក្នុងគណៈកម្មាធិការសម្រាប់រយៈពេល០៤ឆ្នាំ និងអាចមានសិទ្ធិឈរឈ្មោះបោះឆ្នោតភ្លាមៗតែម្តងទៀតទេ។

២- ដោយមិនគិតពីបទប្បញ្ញត្តិនៃវាក្យខ័ណ្ឌ ១ អាណត្តិរបស់សមាជិកពាក់កណ្តាល ដែលត្រូវបានជ្រើសរើសនៅក្នុងការបោះឆ្នោតលើកទីមួយ ត្រូវបញ្ចប់នៅពេលចុងសម័យប្រជុំសាមញ្ញលើកទីមួយ នៃកិច្ចប្រជុំរបស់រដ្ឋភាគី ដែលបន្ទាប់ពីកិច្ចប្រជុំនោះ ពួកគេត្រូវបានជាប់ឆ្នោត។ សមាជិកទាំងនេះត្រូវជ្រើសរើសដោយការចាប់សន្លឹកឆ្នោតដោយប្រធាននៃកិច្ចប្រជុំនេះ ក្រោយពីការបោះឆ្នោតលើកទីមួយ។

មាត្រា ២៦.- បទបញ្ជាផ្ទៃក្នុង

១- គណៈកម្មាធិការត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។

២- ចំនួនភាគច្រើននៃសមាជិកបង្កើតបានជាកូរ៉ុម។ សេចក្តីសម្រេចរបស់គណៈកម្មាធិការត្រូវធ្វើឡើងដោយសំឡេងភាគច្រើន ពីរភាគបីនៃសមាជិកដែលបោះឆ្នោត។

៣- សមាជិកទាំងឡាយមិនត្រូវចូលរួមនៅក្នុងការបោះឆ្នោតលើសេចក្តីសម្រេចណាមួយ ពាក់ព័ន្ធទៅនឹងសម្បត្តិវប្បធម៌ដែលរងការប៉ះពាល់ដោយជម្លោះប្រដាប់អាវុធ ដែលពួកគេជាភាគីនៃជម្លោះនោះឡើយ។

### មាត្រា ២៧.- មុខងារ

១- គណៈកម្មាធិការត្រូវបំពេញមុខងារដូចខាងក្រោម ៖

ក- រៀបចំគោលការណ៍ណែនាំសម្រាប់អនុវត្តន៍ពិធីសារនេះ

ខ- ផ្តល់ជូន ព្យួរទុក ឬលុបចោលនូវការការពារកម្រិតខ្ពស់សម្រាប់សម្បត្តិវប្បធម៌ និងបង្កើត ថែរក្សា និងផ្សព្វផ្សាយបញ្ជីសម្បត្តិវប្បធម៌ដែលស្ថិតក្រោមការការពារកម្រិតខ្ពស់

គ- តាមដាននិងត្រួតពិនិត្យការអនុវត្តពិធីសារនេះ និងផ្សព្វផ្សាយអត្តសញ្ញាណកម្មសម្បត្តិវប្បធម៌ដែលស្ថិតក្រោមការការពារកម្រិតខ្ពស់

ឃ-ពិនិត្យពិចារណា និងផ្តល់យោបល់លើរបាយការណ៍របស់រដ្ឋភាគី ក្នុងគោលបំណងសួររកការបំភ្លឺតាមការចាំបាច់និងរៀបចំរបាយការណ៍ផ្ទាល់របស់គណៈកម្មាធិការស្តីពីការអនុវត្តពិធីសារនេះ សម្រាប់កិច្ចប្រជុំរបស់រដ្ឋភាគី

ង- ទទួល និងពិចារណាលើសំណើសុំជំនួយអន្តរជាតិ ស្របតាមមាត្រា ៣២

ច- កំណត់ការប្រើប្រាស់មូលនិធិ

ឆ- បំពេញមុខងារផ្សេងៗទៀត ដែលកិច្ចប្រជុំរបស់រដ្ឋភាគីអាចប្រគល់ជូន។

២- គណៈកម្មាធិការត្រូវបំពេញមុខងារ ដោយសហការជាមួយអគ្គនាយក។

៣- គណៈកម្មាធិការត្រូវសហប្រតិបត្តិការជាមួយអង្គការក្រៅរដ្ឋាភិបាលជាតិនិងអន្តរជាតិ ដែលមានគោលបំណងស្របគ្នាទៅនឹងគោលបំណងរបស់អនុសញ្ញា ពិធីសារទីមួយនៃអនុសញ្ញា និងពិធីសារនេះ។ ដើម្បីជួយដល់ការបំពេញមុខងាររបស់ខ្លួន គណៈកម្មាធិការអាចអញ្ជើញឲ្យចូលរួមក្នុងកិច្ចប្រជុំរបស់ខ្លួនក្នុងឋានៈជាអ្នកផ្តល់យោបល់ នូវស្ថាប័នវិជ្ជាជីវៈជាន់ខ្ពស់ ដូចជាស្ថាប័នដែលមានទំនាក់ទំនងផ្លូវការជាមួយអង្គការយូណេស្កូ រួមមាន គណៈកម្មាធិការអន្តរជាតិសម្រាប់ស្លាកសញ្ញាខៀវ (International Committee for Blue Shield - ICBS) និងអង្គភាពសំខាន់ៗរបស់គណៈកម្មាធិការនេះ។ តំណាងរបស់មជ្ឈមណ្ឌលអន្តរជាតិសម្រាប់សិក្សាអំពីការអភិរក្សនិងជួសជុលសម្បត្តិវប្បធម៌ (International Center for the Study of the Preservation and Restoration of Cultural Property – Rome Center - ICCROM) និងតំណាងគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ (International Committee of the Red Cross - ICRC) ក៏អាចត្រូវបានអញ្ជើញឲ្យចូលរួមកិច្ចប្រជុំផងដែរក្នុងឋានៈជាស្ថាប័នពិគ្រោះយោបល់។

### មាត្រា ២៨.- លេខាធិការដ្ឋាន

គណៈកម្មាធិការត្រូវបានជួយកិច្ចការដោយលេខាធិការដ្ឋានរបស់អង្គការយូណេស្កូ ដែលត្រូវរៀបចំឯកសារ និងរបៀបវារៈប្រជុំរបស់គណៈកម្មាធិការ និងត្រូវមានការទទួលខុសត្រូវសម្រាប់ការអនុវត្តសេចក្តីសម្រេចរបស់គណៈកម្មាធិការ។

### មាត្រា ២៩.- មូលនិធិសម្រាប់ការការពារសម្បត្តិវប្បធម៌ក្នុងគ្រាមានជម្លោះប្រដាប់អាវុធ

១- មូលនិធិមួយត្រូវបានបង្កើតឡើងតាមស្មារតីនៃពិធីសារនេះសម្រាប់បម្រើឲ្យគោលបំណងដូចខាង

ក្រោម ៖

ក- ផ្តល់ជំនួយហិរញ្ញវត្ថុ ឬជំនួយផ្សេងទៀត ដើម្បីគាំទ្រដល់វិធានការត្រៀមទុកជាមុន ឬវិធានការផ្សេងទៀត ដែលត្រូវធ្វើឡើងនៅពេលមានសន្តិភាព ស្របតាមមាត្រា ១០ អនុវាក្យខំណ្ឌ (ខ) និង មាត្រា ៣០ និងមាត្រាផ្សេងៗទៀត

ខ- ផ្តល់ជំនួយហិរញ្ញវត្ថុ ឬជំនួយផ្សេងទៀតក្នុងគ្រាមានអាសន្ន វិធានការបណ្តោះអាសន្ន ឬវិធានការផ្សេងទៀតដែលត្រូវធ្វើឡើង ដើម្បីការពារសម្បត្តិវប្បធម៌ ក្នុងអំឡុងពេលមានជម្លោះប្រដាប់អាវុធ ឬការរួចចាកផុតភ្លាមៗពីការបញ្ចប់ភាពប្រទូសរ៉ាយ ស្របតាមមាត្រា ៨ អនុវាក្យខំណ្ឌ (ក) និងមាត្រាផ្សេងៗទៀត ។

២- មូលនិធិនេះគឺជាមូលនិធិអាណត្តិព្យាបាលភាព (Trust Fund) ស្របតាមបទប្បញ្ញត្តិនៃនិយ័តកម្មហិរញ្ញវត្ថុរបស់អង្គការយូណេស្កូ។

៣- ការបើកប្រាក់ចំណាយចេញពីមូលនិធិ ត្រូវបានប្រើប្រាស់សម្រាប់តែគោលបំណង ដែលគណៈកម្មាធិការសម្រេចស្របតាមគោលការណ៍ណែនាំ ដូចមានចែងក្នុងមាត្រា ២៣ អនុវាក្យខំណ្ឌ ៣(គ)ប៉ុណ្ណោះ។ គណៈកម្មាធិការអាចទទួលយកប្រាក់វិភាគទានមកប្រើប្រាស់តែសម្រាប់កម្មវិធី ឬគម្រោងដែលប្រាកដប៉ុណ្ណោះ ឲ្យតែគណៈកម្មាធិការបានសម្រេចរួចហើយលើការអនុវត្តកម្មវិធី ឬគម្រោងបែបនោះ។

៤- ធនធានទាំងអស់របស់មូលនិធិរួមមាន ៖

ក- ប្រាក់វិភាគទានស្ម័គ្រចិត្តរបស់រដ្ឋភាគី

ខ- ប្រាក់វិភាគទាន អំណោយទាន ដែលផ្តល់ជូនដោយ ៖

(១) រដ្ឋផ្សេងៗទៀត

(២) អង្គការយូណេស្កូ ឬស្ថាប័នផ្សេងៗទៀតនៃប្រព័ន្ធអង្គការសហប្រជាជាតិ

(៣) អង្គការអន្តររដ្ឋាភិបាល ឬមិនមែនរដ្ឋាភិបាល

(៤) ស្ថាប័នសាធារណៈ ឬឯកជន ឬបុគ្គល

គ- ការប្រាក់ដែលកើនឡើងលើមូលនិធិ

ឃ-មូលនិធិដែលរកបានតាមរយៈការរៃអង្គាស និងប្រាក់ទទួលបានពីព្រឹត្តិការណ៍ផ្សេងៗដែលរៀបចំឡើងដើម្បីជាប្រយោជន៍នៃមូលនិធិ និង

ង- ធនធានផ្សេងៗទៀតដែលទទួលបានការអនុញ្ញាតដោយគោលការណ៍ណែនាំ ដែលត្រូវអនុវត្តចំពោះមូលនិធិ។

## ជំពូកទី ៧
## ការផ្សព្វផ្សាយព័ត៌មាន និងជំនួយអន្តរជាតិ

មាត្រា ៣០.- ការផ្សព្វផ្សាយព័ត៌មាន

១- រដ្ឋភាគីទាំងឡាយត្រូវខិតខំប្រឹងប្រែងតាមមធ្យោបាយសមស្រប និងជាពិសេសតាមរយៈកម្មវិធីអប់រំនិងព័ត៌មាន ដើម្បីឲ្យប្រជាជនទាំងអស់របស់ពួកគេបង្កើននូវការវាយតម្លៃខ្ពស់ និងការគោរពចំពោះសម្បត្តិវប្បធម៌។

២- រដ្ឋភាគីទាំងឡាយត្រូវផ្សព្វផ្សាយពិធីសារនេះឲ្យបានទូលំទូលាយតាមដែលអាចធ្វើទៅបាន ទាំងក្នុងពេលមានសន្តិភាព និងក្នុងគ្រាមានជម្លោះប្រដាប់អាវុធ។

៣- អាជ្ញាធរយោធា ឬស៊ីវិលណាមួយដែលទទួលខុសត្រូវក្នុងការអនុវត្តពិធីសារនេះ ក្នុងពេលមានជម្លោះប្រដាប់អាវុធត្រូវយល់ជ្រួតជ្រាបអំពីអត្ថបទនៃពិធីសារនេះទាំងស្រុង។ ក្នុងគោលដៅនេះតាមការចាំបាច់ រដ្ឋភាគីត្រូវ ៖

ក- បញ្ចូលគោលការណ៍ប្រតិបត្តិ និងការណែនាំស្តីពីការការពារសម្បត្តិវប្បធម៌ នៅក្នុងបទប្បញ្ញត្តិនានារបស់យោធា

ខ- រៀបចំ និងអនុវត្តកម្មវិធីអប់រំ និងហ្វឹកហ្វឺនពេលមានសន្តិភាព ដោយសហការជាមួយអង្គការយូណេស្កូ និងស្ថាប័នរដ្ឋាភិបាល និងក្រៅរដ្ឋាភិបាលពាក់ព័ន្ធ

គ- ផ្តល់ឲ្យគ្នាទៅវិញទៅមកតាមរយៈអគ្គនាយកអង្គការយូណេស្កូ នូវព័ត៌មានអំពីច្បាប់បទប្បញ្ញត្តិរដ្ឋបាល និងវិធានការនានា ដែលត្រូវបានធ្វើឡើងស្របតាមអនុវាក្យខណ្ឌ (ក) និង (ខ)

ឃ-ផ្តល់ឲ្យគ្នាទៅវិញទៅមកឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន តាមរយៈអគ្គនាយកអង្គការយូណេស្កូនូវព័ត៌មានអំពីច្បាប់ និងបទប្បញ្ញត្តិរដ្ឋបាល ដែលពួកគេអាចអនុម័ត ដើម្បីធានាឲ្យបាននូវការអនុវត្តពិធីសារនេះ។

មាត្រា ៣១.- កិច្ចសហប្រតិបត្តិការអន្តរជាតិ

ក្នុងស្ថានភាពនៃការរំលោភធ្ងន់ធ្ងរលើពិធីសារនេះ រដ្ឋភាគីទាំងឡាយខិតខំធ្វើការរួមគ្នា តាមរយៈគណៈកម្មាធិការ ឬដាច់ដោយឡែក ដោយសហការជាមួយអង្គការយូណេស្កូ និងអង្គការសហប្រជាជាតិ និងស្របតាមធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ។

មាត្រា ៣២.- ជំនួយអន្តរជាតិ

១- រដ្ឋភាគីមួយអាចស្នើសុំពីគណៈកម្មាធិការនូវជំនួយអន្តរជាតិសម្រាប់សម្បត្តិវប្បធម៌ ដែលស្ថិតក្រោមការការពារកម្រិតខ្ពស់ ក៏ដូចជាជំនួយដែលពាក់ព័ន្ធនឹងការរៀបចំ ការកសាង ឬការអនុវត្តច្បាប់ បទប្បញ្ញត្តិរដ្ឋបាល និងវិធានការនានាដូចបានលើកឡើងក្នុងមាត្រា ១០។

២- ភាគីមួយនៃជម្លោះដែលមិនមែនជារដ្ឋភាគីនៃពិធីសារនេះ ប៉ុន្តែសុខចិត្តទទួលយក និងអនុវត្តបទប្បបញ្ញត្តិទាំងឡាយស្របតាមមាត្រា ៣ វាក្យខណ្ឌ ២ អាចស្នើសុំជំនួយអន្តរជាតិសមស្របពីគណៈកម្មាធិការ។

៣- គណៈកម្មាធិការត្រូវអនុម័តវិធាននានាសម្រាប់ការដាក់ស្នើសុំជំនួយអន្តរជាតិ និងត្រូវកំណត់អំពីទម្រង់នៃជំនួយអន្តរជាតិ។

៤- រដ្ឋភាគីទាំងឡាយត្រូវបានលើកទឹកចិត្តឲ្យផ្តល់ជំនួយបច្ចេកទេសគ្រប់បែបយ៉ាង តាមរយៈគណៈកម្មាធិការ ទៅដល់រដ្ឋភាគីទាំងឡាយ ឬរដ្ឋភាគីនៃជម្លោះដែលស្នើសុំជំនួយ។

មាត្រា ៣៣.- ជំនួយរបស់អង្គការយូណេស្កូ

១- រដ្ឋភាគីមួយអាចស្នើសុំជំនួយបច្ចេកទេសពីអង្គការយូណេស្កូ ក្នុងការរៀបចំការការពារសម្បត្តិវប្បធម៌របស់ខ្លួន ដូចជាសកម្មភាពត្រៀមរៀបចំដើម្បីការពារសម្បត្តិវប្បធម៌ វិធានការបង្ការទុកជាមុន និងរៀបចំសម្រាប់គ្រាមានអាសន្ន និងការរៀបចំចងក្រងបញ្ជីសារពើភណ្ឌសម្បត្តិវប្បធម៌ ឬក៏ពាក់ព័ន្ធនឹងបញ្ហាណាមួយផ្សេងទៀតដែលកើតចេញមកពីការអនុវត្តពិធីសារនេះ។ អង្គការយូណេស្កូត្រូវផ្តល់ជំនួយបែបនេះ នៅក្នុងដែនកំណត់មួយដោយកម្មវិធី និងធនធានរបស់ខ្លួន។

២- រដ្ឋភាគីទាំងឡាយត្រូវបានលើកទឹកចិត្តឲ្យផ្តល់ជំនួយបច្ចេកទេសក្នុងកម្រិតទ្វេភាគី ឬពហុភាគី។

៣- តាមគំនិតផ្តួចផ្តើមរបស់ខ្លួន អង្គការយូណេស្កូត្រូវបានអនុញ្ញាតឲ្យលើកសំណើស្តីពីបញ្ហាទាំងនេះ ទៅរដ្ឋភាគីទាំងឡាយ។

## ជំពូកទី ៨
## ការអនុវត្តពិធីសារនេះ

**មាត្រា ៣៤.-** ប្រទេសមហាអំណាច

ពិធីសារនេះ ត្រូវអនុវត្តជាមួយនឹងកិច្ចសហប្រតិបត្តិការពីប្រទេសមហាអំណាច ដែលទទួលខុសត្រូវក្នុងការការពារផលប្រយោជន៍របស់ភាគីទាំងឡាយនៃជម្លោះ។

**មាត្រា ៣៥.-** នីតិវិធីផ្សះផ្សា

១- ប្រទេសមហាអំណាចត្រូវផ្តល់តួនាទីផ្សះផ្សារបស់ពួកគេនៅក្នុងគ្រប់ករណីទាំងអស់ ដែលគេចាត់ទុកថាមានសារៈប្រយោជន៍សម្រាប់សម្បត្តិវប្បធម៌ ជាពិសេសប្រសិនបើមានការមិនចុះសម្រុងគ្នារវាងភាគីទាំងឡាយនៃជម្លោះពាក់ព័ន្ធនឹងការអនុវត្ត ឬការបកស្រាយបទប្បញ្ញត្តិនៃពិធីសារនេះ។

២- សម្រាប់គោលបំណងនេះ ប្រទេសមហាអំណាចនីមួយៗ អាចតាមរយៈការស្នើសុំរបស់ភាគីមួយ ឬរបស់អគ្គនាយក ឬតាមគំនិតផ្តួចផ្តើមផ្ទាល់របស់ខ្លួន អាចស្នើទៅភាគីទាំងឡាយនៃជម្លោះឲ្យមានកិច្ចប្រជុំមួយនៅលើទឹកដីរបស់រដ្ឋមួយដែលមិនមែនជាភាគីនៃជម្លោះ តំណាងរបស់ពួកគេនិងជាពិសេសរបស់អាជ្ញាធរដែលទទួលខុសត្រូវសម្រាប់ការការពារសម្បត្តិវប្បធម៌ ប្រសិនបើយល់ថាសមស្រប។ ភាគីទាំងឡាយនៃជម្លោះត្រូវតែកាតព្វកិច្ចគោរពទៅតាមសំណើឲ្យមានកិច្ចប្រជុំដែលត្រូវបានស្នើមកពួកគេ។ ប្រទេសមហាអំណាចត្រូវស្នើសុំឲ្យភាគីទាំងឡាយនៃជម្លោះ ឯកភាពលើបុគ្គលម្នាក់មានសញ្ជាតិរបស់រដ្ឋមួយ ដែលមិនមែនជាភាគីនៃជម្លោះ ឬបុគ្គលម្នាក់ដែលស្នើឡើងដោយអគ្គនាយក ដែលបុគ្គលនោះត្រូវអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចប្រជុំបែបនេះក្នុងឋានៈជាប្រធានអង្គប្រជុំ។

**មាត្រា ៣៦.-** ការផ្សះផ្សាដោយគ្មានប្រទេសមហាអំណាច

១- នៅក្នុងជម្លោះមួយដែលគ្មានប្រទេសមហាអំណាចចូលរួមផ្សះផ្សា អគ្គនាយកអាចមានតួនាទីជាអ្នកសម្របសម្រួល ឬបំពេញមុខងារណាមួយផ្សេងទៀតក្នុងទម្រង់ជាការផ្សះផ្សា ឬមជ្ឈត្តការី ក្នុងគោលបំណងដោះស្រាយការមិនចុះសម្រុងគ្នា។

២- តាមសំណើរបស់ភាគីមួយ ឬរបស់អគ្គនាយក ប្រធានគណៈកម្មាធិការអាចស្នើទៅភាគីទាំងឡាយនៃជម្លោះឲ្យមានកិច្ចប្រជុំមួយរបស់តំណាងពួកគេ និងជាពិសេសរបស់អាជ្ញាធរដែលទទួលខុសត្រូវសម្រាប់ការការពារសម្បត្តិវប្បធម៌ ប្រសិនបើយល់ថាសមស្រប នៅលើទឹកដីរបស់រដ្ឋមួយដែលមិនមែនជាភាគីនៃជម្លោះ។

**មាត្រា ៣៧.-** ការបកប្រែ និងរបាយការណ៍

១- រដ្ឋភាគីទាំងឡាយត្រូវបកប្រែពិធីសារនេះទៅជាភាសាផ្លូវការរបស់ពួកគេ និងបញ្ជូនអត្ថបទបកប្រែផ្លូវការទាំងនេះមកអគ្គនាយក។

២- រដ្ឋភាគីទាំងឡាយត្រូវដាក់ជូនទៅគណៈកម្មាធិការនៅរៀងរាល់បួនឆ្នាំម្តង នូវរបាយការណ៍ស្តីពីការអនុវត្តពិធីសារនេះ។

មាត្រា ៣៨.- ការទទួលខុសត្រូវរបស់រដ្ឋ

គ្មានបទប្បញ្ញត្តិណាមួយនៃពិធីសារនេះ ស្តីពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់បុគ្គល ដែលប៉ះពាល់ដល់ការទទួលខុសត្រូវរបស់រដ្ឋទៅតាមច្បាប់អន្តរជាតិនោះឡើយ រួមទាំងករណីកិច្ចជួសជុលសងវិញទៀតផង។

## ជំពូកទី ៩
## អវសានប្បញ្ញត្តិ

មាត្រា ៣៩.- ភាសា

ពិធីសារនេះត្រូវបានរៀបចំឡើងជាភាសា អារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ៉ុល ហើយអត្ថបទទាំងប្រាំមួយភាសានេះមានតម្លៃស្មើគ្នា។

មាត្រា ៤០.- ហត្ថលេខា

ពិធីសារនេះត្រូវចុះកាលបរិច្ឆេទនៅថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៩៩។ ពិធីសារនេះត្រូវបានអនុញ្ញាតឲ្យចុះហត្ថលេខាដោយភាគីហត្ថលេខីទាំងអស់ នៅទីក្រុងឡាអេ ចាប់ពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៩៩ ដល់ទី៣១ ខែធ្នូ ឆ្នាំ១៩៩៩។

មាត្រា ៤១.- ការផ្តល់សច្ចាប័ន ការទទួលយក ឬ ការយល់ព្រម

១- ពិធីសារនេះដាក់ឲ្យផ្តល់សច្ចាប័ន ទទួលយក ឬយល់ព្រម ដោយភាគីហត្ថលេខីទាំងឡាយ ដែលបានចុះហត្ថលេខាលើពិធីសារនេះ ស្របទៅតាមនីតិវិធីដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញរបស់រដ្ឋនីមួយៗ។

២- លិខិតូបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលយក ឬការយល់ព្រម ត្រូវតម្កល់ទុកនៅនឹងអគ្គនាយក។

មាត្រា ៤២.- ការចូលជាសមាជិក

១- ពិធីសារនេះត្រូវបានអនុញ្ញាតឲ្យចូលជាសមាជិកដោយភាគីហត្ថលេខីផ្សេងទៀត ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០០។

២- ការចូលជាសមាជិកនឹងមានប្រសិទ្ធភាព ក្រោយពេលតម្កល់ទុកលិខិតូបករណ៍ចូលជាសមាជិកនៅនឹងអគ្គនាយក។

មាត្រា ៤៣.- ការចូលជាធរមាន

១- ពិធីសារនេះចូលជាធរមានបីខែក្រោយពីការតម្កល់លិខិតូបករណ៍ទី២០នៃការផ្តល់សច្ចាប័ន ការទទួលយក និងការយល់ព្រម ឬការចូលជាសមាជិក។

២- ក្រោយពីនេះទៅ ពិធីសារនេះចូលជាធរមានចំពោះរដ្ឋភាគីនីមួយៗរយៈពេលបីខែក្រោយពីតម្កល់លិខិតូបករណ៍របស់ខ្លួននៃការផ្តល់សច្ចាប័ន ការទទួលយក ការយល់ព្រម ឬការចូលជាសមាជិក។

មាត្រា ៤៤.- ការចូលជាធរមាននៅក្នុងស្ថានភាពនៃជម្លោះប្រដាប់អាវុធ

ស្ថានភាពទាំងឡាយដែលត្រូវបានលើកឡើងក្នុងមាត្រា ១៨ និង ១៩ នៃអនុសញ្ញា ត្រូវចូលជាធរមានភ្លាម ដើម្បីផ្តល់សច្ចាប័ន ទទួលយក យល់ព្រម ឬចូលជាសមាជិកនៃពិធីសារនេះ ដែលភាគីទាំងឡាយនៃ

ជម្លោះបានតម្កល់ ទោះនៅមុន ឬក្រោយការចាប់ផ្តើមភាពប្រទូសរ៉ាយ ឬការកាន់កាប់។ នៅក្នុងករណីបែបនេះ អគ្គនាយកត្រូវជូនដំណឹងឲ្យបានលឿនបំផុត ដូចមានចែងក្នុងមាត្រា ៤៦។

មាត្រា ៤៥.- **ការប្រកាសបដិសេធ**

១- រដ្ឋភាគីនីមួយៗអាចប្រកាសបដិសេធពិធីសារនេះ។

២- ការប្រកាសបដិសេធនេះ ត្រូវជូនដំណឹងដោយលិខិតូបករណ៍ជាលាយលក្ខណ៍អក្សរ ដែលត្រូវតម្កល់ទុកនៅនឹងអគ្គនាយក។

៣- ការប្រកាសបដិសេធត្រូវចូលជាធរមានមួយឆ្នាំក្រោយមក បន្ទាប់ពីបានទទួលលិខិតូបករណ៍ប្រកាសបដិសេធ។ តែទោះជាយ៉ាងណាក៏ដោយ នៅពេលផុតសុពលភាពនៃរយៈពេលនេះ ប្រសិនបើរដ្ឋភាគីដែលប្រកាសបដិសេធនេះកំពុងមានជម្លោះប្រដាប់អាវុធ ការប្រកាសបដិសេធត្រូវចូលជាធរមាននៅពេលបញ្ចប់ភាពប្រទូសរ៉ាយ ឬរហូតទាល់តែប្រតិបត្តិការបញ្ជូនត្រឡប់មកវិញនូវសម្បត្តិវប្បធម៌ត្រូវបានបញ្ចប់ ដែលមួយណាក៏ដោយឲ្យតែត្រូវបានបញ្ចប់។

មាត្រា ៤៦.- **ការជូនដំណឹង**

អគ្គនាយកត្រូវជូនព័ត៌មានដល់គ្រប់ភាគីហត្ថលេខី ព្រមទាំងអង្គការសហប្រជាជាតិ អំពីការតម្កល់លិខិតូបករណ៍ទាំងអស់នៃការផ្តល់សច្ចាប័ន ការទទួលយក ការយល់ព្រម ឬការចូលជាសមាជិក ដូចមានចែងក្នុងមាត្រា ៤១ និង ៤២ និងអំពីការប្រកាសបដិសេធ ដូចមានចែងក្នុងមាត្រា ៤៥។

មាត្រា ៤៧.- **ការចុះបញ្ជីនៅអង្គការសហប្រជាជាតិ**

ស្របតាមមាត្រា ១០២ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ពិធីសារនេះនឹងត្រូវចុះបញ្ជីនៅលេខាធិការដ្ឋានរបស់អង្គការសហប្រជាជាតិ យោងតាមសំណើរបស់អគ្គនាយក។

**ដើម្បីជាសក្ខីភាព** តំណាងដែលទទួលសិទ្ធិស្របច្បាប់ បានចុះហត្ថលេខាលើពិធីសារនេះ។

**ធ្វើនៅទីក្រុងឡាអេ** នាថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៩៩ ជាច្បាប់តែមួយ ដែលត្រូវតម្កល់ទុកនៅក្នុងបណ្ណសារដ្ឋានរបស់អង្គការយូណេស្កូ ហើយច្បាប់ចម្លងដែលបញ្ជាក់ថាត្រឹមត្រូវ នឹងត្រូវចែកជូនដល់គ្រប់ភាគីហត្ថលេខី។

ពិធីសារនេះត្រូវបានចុះហត្ថលេខាដោយបណ្តារដ្ឋដូចខាងក្រោមៈ

| | |
|---|---|
| - អាល់បានី | ២៦ ខែមីនា ឆ្នាំ១៩៩៩ |
| - អាមេនី | ២៧ ខែតុលា ឆ្នាំ១៩៩៩ |
| - អូទ្រីស | ២៦ ខែមីនា ឆ្នាំ១៩៩៩ |
| - បេឡារុស | ២៦ ខែមីនា ឆ្នាំ១៩៩៩ |
| - បែលហ្ស៊ិក | ២៦ ខែមីនា ឆ្នាំ១៩៩៩ |
| - ប៊ុលហ្គារី | ១៩ ខែកញ្ញា ឆ្នាំ ១៩៩៩ |
| - កម្ពុជា | ២៦ ខែមីនា ឆ្នាំ១៩៩៩ |
| - កូឡុំប៊ី | ៣១ ខែធ្នូ ឆ្នាំ១៩៩៩ |
| - កូតឌីវ័រ | ២៦ ខែមីនា ឆ្នាំ១៩៩៩ |
| - ក្រូអាស៊ី | ២៦ ខែមីនា ឆ្នាំ១៩៩៩ |
| - ស៊ីប | ១៩ ខែសីហា ឆ្នាំ១៩៩៩ |
| - អេក្វាឌ័រ | ២៩ ខែធ្នូ ឆ្នាំ១៩៩៩ |
| - អេហ្ស៊ីប | ២៩ ខែតុលា ឆ្នាំ១៩៩៩ |
| - អេស្តូនី | ២៦ ខែមីនា ឆ្នាំ១៩៩៩ |
| - ហ្វាំងឡង់ | ២៦ ខែ មីនា ឆ្នាំ ១៩៩៩ |
| - អាល្លឺម៉ង់ | ២៦ ខែ មីនា ឆ្នាំ ១៩៩៩ |
| - ហ្គាណា | ២៦ ខែមីនា ឆ្នាំ១៩៩៩ |
| - ក្រិក | ២៦ ខែ មីនា ឆ្នាំ ១៩៩៩ |
| - ហូលីស៊ី | ២៦ ខែមីនា ឆ្នាំ១៩៩៩ |
| - ហុងគ្រី | ២៦ ខែមីនា ឆ្នាំ១៩៩៩ |
| - ឥណ្ឌូណេស៊ី | ២៦ ខែ មីនា ឆ្នាំ ១៩៩៩ |
| - អ៊ីតាលី | ២៦ ខែមីនា ឆ្នាំ១៩៩៩ |
| - លុចសំបួ | ២៦ ខែមីនា ឆ្នាំ១៩៩៩ |
| - ម៉ាដាហ្គាស្កា | ២៦ ខែមីនា ឆ្នាំ១៩៩៩ |
| - មារ៉ុក | ២១ ខែធ្នូ ឆ្នាំ១៩៩៩ |
| - ហូឡង់ | ២៦ ខែមីនា ឆ្នាំ១៩៩៩ |
| - នីហ្សេរីយ៉ា | ២៦ ខែមីនា ឆ្នាំ១៩៩៩ |
| - អូម៉ង់ | ៣០ ខែមិថុនា ឆ្នាំ១៩៩៩ |
| - ប៉ាគីស្ថាន | ២៦ ខែមីនា ឆ្នាំ១៩៩៩ |
| - ប៉េរូ | ១៣ ខែកក្កដា ឆ្នាំ១៩៩៩ |
| - កាតា | ២៦ ខែមីនា ឆ្នាំ១៩៩៩ |
| - រ៉ូមានី | ០៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ |
| - សាធារណរដ្ឋស្លូវ៉ាគី | ២៧ ខែធ្នូ ឆ្នាំ១៩៩៩ |
| - អេស្ប៉ាញ | ២៦ ខែមីនា ឆ្នាំ១៩៩៩ |

- ស៊ុយអែត ២៦ ខែមីនា ឆ្នាំ១៩៩៩
- ស្វីស ២៦ ខែមីនា ឆ្នាំ១៩៩៩
- ស៊ីរី ២៦ ខែមីនា ឆ្នាំ១៩៩៩
- យេម៉ែន ២៦ ខែមីនា ឆ្នាំ១៩៩៩

**ការចូលជាធរមាន៖** ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០០៤ ស្របតាមមាត្រា ៤៣.១

**អត្ថបទផ្លូវការ៖** ភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ៉ុល

**ការចុះបញ្ជីនៅអង្គការសហប្រជាជាតិ៖** ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៤ លេខ៖ ៣៥១១

# Second Protocol to the Hague Convention of 1954 for the Protection of Cultural Property in the Event of Armed Conflict 1999

The Hague, 26 march 1999
-Convention, The Hague 14 May 1954
-First Protocol, The Hague, 14 May 1954

The Parties,

**Conscious** of the need to improve the protection of cultural property in the event of armed conflict and to establish an enhanced system of protection for specifically designated cultural property;

**Reaffirming** the importance of the provisions of the Convention for the Protection of Cultural Property in the Event of Armed Conflict, done at the Hague on 14 May 1954, and emphasizing the necessity to supplement these provisions through measures to reinforce their implementation;

**Desiring** to provide the High Contracting Parties to the Convention with a means of being more closely involved in the protection of cultural property in the event of armed conflict by establishing appropriate procedures therefor;

**Considering** that the rules governing the protection of cultural property in the event of armed conflict should reflect developments in international law;

**Affirming** that the rules of customary international law will continue to govern questions not regulated by the provisions of this Protocol;

**Have agreed as follows:**

## Chapter 1 Introduction

### Article 1 Definitions

For the purposes of this Protocol:

a. "Party" means a State Party to this Protocol;

b. "cultural property" means cultural property as defined in Article 1 of the Convention;

c. "Convention" means the Convention for the Protection of Cultural Property in the Event of Armed Conflict, done at The Hague on 14 May 1954;

d. "High Contracting Party" means a State Party to the Convention;

e. "enhanced protection" means the system of enhanced protection established by Articles 10 and 11;

f. "military objective" means an object which by its nature, location, purpose, or use makes an effective contribution to military action and whose total or partial destruction, capture or neutralisation, in the circumstances ruling at the time, offers a definite military advantage;

g. "illicit" means under compulsion or otherwise in violation of the applicable rules of the domestic law of the occupied territory or of international law.

h. "List" means the International List of Cultural Property under Enhanced Protection established in accordance with Article 27, sub-paragraph 1(b);

i. "Director-General" means the Director-General of UNESCO;

j. "UNESCO" means the United Nations Educational, Scientific and Cultural Organization;

k. "First Protocol" means the Protocol for the Protection of Cultural Property in the Event of Armed Conflict done at The Hague on 14 May 1954;

**Article 2 Relation to the Convention**

This Protocol supplements the Convention in relations between the Parties.

**Article 3 Scope of application**

